# ខ្យល់វង្វេងវង្វរ

ភាកគតិ

ល្អអ្វីល្អម្ល៉េះ ល្អអូនពិសេស លើសពេជ្រចរណៃ
ឲ្យបងវង្វេង គេងយប់គេងថ្ងៃ គេងឱបកើយដៃ
ក្បៀយមិនសោកស្តាយ។

បើបាត់ពុកម៉ែ សត្វបឹងដីស្រែ ឬញាតិជិតឆ្ងាយ
បងយំមួយរឹង នឹងអស់ការស្តាយ បើបាត់ឆោមឆាយ
បងស្តាយលុះសូន្យ។

បងចាកចោលផ្ទះ ប្រពន្ធបងលះ ឱយតែជិតអូន
លក់គ្រប់ដីស្រែ គោទាំងមេកូន សុំរត់តាមអូន
តែម្នាក់គូរអាយ។

បើអូនខ្លាចស្លាប់ បងវិលវៃឆាប់ ទៅគាស់កកាយ
កំណប់កេរ្តិ៍ឪ កប់ស្រុកជិតឆ្ងាយ ទុកបង្កាចាយ
សប្បាយអូនបង។

បើពុកម៉ែស្នួន បំបែកនឹមន្ទ ឲ្យផ្តាច់ចំណង
មកនៅខាងប្តី ស្រីកុំសៅហ្មង ដីកេរ្តិ៍ប្រុសបង
លក់ចាយដប់ជាតិ។

បើញាតិផងពៅ អូនគ្មានដីនៅ កុំគិតចង្អៀត
នាំមកនៅចុះ បងមិនបៀនបៀត បងរាប់ជាញាតិ
ដូចជាអូនដែរ។

អូនចង់សុំអី សេះគោដំរី ជ្រូកឬក៏ឆ្កែ
ទន្លេបឹងបួរ ឬចំការស្រែ ព្រោះអីមានតែ
បងទេដែលធំ។

សុំអីក៏បាន ឲ្យតែកល្យាណ អូននាងជួបជុំ
ជាមួយប្រុសបង មូលជាទ្រនំ ទ្រព្យបងជិតជុំ
ឲ្យមិនស្រណោះ។

ផ្ទះបងចង្អៀត បងសុំផ្ទះញាតិ ដេកគ្រាន់ស្រាយដោះ
និយាយឲ្យចំ ឲ្យតែអូនស្មោះ ទ្រព្យបងទាំងអស់
ជារបស់អូន។

ពុកខ្ញុំពីដើម ល្បាញល្បីសម្បើម ពីរោះដល់កូន
មានផ្ទះធំខ្ពស់ រស់ជុំតាដូន គោរាប់រយផ្លូន
ក្របីរាប់លាន។

ដំរីរាប់សែន អ្នកឈ្នួលផងផែន ច្រើនជាងទាហាន
ពេជ្ររយជង្រុក មាសអាចធ្វើស្ពាន សាងដប់វិមាន
ក៏មិនលួសស្បើយ។

ដីលានហិតា ដីព្រៃចំការ ចាំមិនអស់ឡើយ
ដើរកាត់ដប់ឆ្នាំ មិនដល់ដែនត្រើយ ខណៈនោះហើយ
ពូជខ្ញុំខ្ទរខ្ទា។

វិមានរយពាន់ ខ្លះសាងទុកគ្រាន់ គោរពបូជា
ខ្លះទុកកំសាន្ត ពេលជួបជុំគ្នា ឬធ្វើការងារ
ពិធីធំៗ។

វិមានចាស់ថ្មី ខ្លះសាងលើដី ខ្លះសាងលើភ្នំ
ខ្លះសាងដោយយាយ ខ្លះសាងដោយអ៊ំ ខ្លះដោយតាខ្ញុំ
គាត់ប្រឹងទុកឈ្មោះ។

កេរ្តិ៍ឈ្មោះតាយាយ ពុកម៉ែរស់ងាយ មានសក្តិខ្ពង់ខ្ពស់
ស៊ីចាយតាមចិត្ត ក៏មានរលួស សប្បុរនេះហួស
ពីក្តីខ្វល់ខ្វាយ។

តែខ្ញុំនេះណា គ្មានភ័ព្វវាសនា ដូចឪពុកម្តាយ
បានតែអ្នកផ្សេង ដែលជាសាច់ឆ្ងាយ ព្រោះពុកដូរម្តាយ
ទៅស្តាយស្រីក្មេង។

ខ្ញុំបានតែសោក ឱបញ្ញាតិទួញបោក រងំស្តាំឆ្វេង
ស្តាយទ្រព្យរបស់ ត្រូវគេកែនកេង បានទៅអ្នកផ្សេង
នឹងភ្នែកភ្លឺស្រស់។

ដល់ពេលឥឡូវ ជង្រុកគ្មានស្រូវ កេរ្តិ៍ស្មើគ្មានសោះ
ស្រូវស៊ីមិនគ្រប់ ខ្លួនស្គមក្សត់ខ្សោះ ជ្រាត់ក្បាលស្រណោះ
មើលគេស៊ីល្បៀង។

គេស៊ីគេចុក គេសើចសោយសុខ គេរាំគេច្រៀង
គេស្វាគមន៍ជ័យ យើងដេកពោះផ្អៀង លិតក្អែលបាតពាង
កំដរថ្ងៃស្លាប់។

ភ្នំពេញ ថ្ងៃទី ២៩ មីនា ២០០៦

សូយ ឡុត